


*ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០២០ #Coronavirus #EUfightsCorona #TeamEurope*

# <u>សេចក្ដីប្រកាសព័ត៌មាន</u>

## *ក្រុមអឺរ៉ុប (#TeamEurope)* គាំទ្រកម្ពុជា ក្នុងអំឡុងវិបត្តិនៃវីរុសកូរ៉ូណា

ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីគាំទ្រដល់បណ្ដាប្រទេសជាដៃគូ ជុំវិញពិភពលោក ក្រុមអឺរ៉ុប (Team Europe*) កំពុងកៀគរថវិកាចំនួន ៩៤៣ លានអឺរ៉ូ ជាជំនួយឥតសំណង និង ប្រាក់កម្ចី ដើម្បីអនុវត្តការងារជាមួយប្រទេសកម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងនឹងការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ ក៏ដូចជា កាត់បន្ថយផលប៉ះពាល់សង្គម សេដ្ឋកិច្ច ដែលបង្កឡើងដោយសារជំងឺនេះ។

ក្រុមអឺរ៉ុប(Team Europe*) គឺជាក្រុមដែលកើតឡើងដោយមានកិច្ចខិតខំបរួមគ្នារបស់សហភាពអឺរ៉ុប ជាមួយរដ្ឋជាសមាជិករបស់ខ្លួន ស្ថាប័នហិរញ្ញវត្ថុ និងទីភ្នាក់ងារអនុវត្តនានា។ ដោយការរួមកំលាំងជាមួយគ្នានេះ ក្រុមអឺរ៉ុបផ្ដល់ជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសដ៏គួរអោយកត់សំគាល់ ដើម្បីជួយកម្ពុជា ឆ្លើយតបទៅនឹងតម្រូវការចំពោះមុខ ដើម្បីការពារក្រុមដែលងាយរងគ្រោះជាងគេ ដើម្បីកាត់បន្ថយផលប៉ះពាល់សង្គមសេដ្ឋកិច្ច ដែលកើតឡើងដោយសារវិបត្តិដែលបង្កឡើងដោយវីរុសកូរ៉ូណា និងត្រៀមខ្លួន ដើម្បីស្តារឡើង វិញ។ ក្នុងប្រទេសកម្ពុជា ក្រុមអឺរ៉ុបធ្វើការរួមគ្នាជាមួយនឹងប្រទេសស្វីស ដែលជាដៃគូអឺរ៉ុបរបស់យើង។

កម្មវិធី និងគម្រោងទាំងអស់ ដែលអនុវត្តដោយក្រុមអឺរ៉ុប សុទ្ធតែរួមចំណែកដល់ការលើកកម្ពស់ គោលការណ៍ប្រជាធិបតេយ្យ ការលើកកម្ពស់និងការពារសិទ្ធិមនុស្ស និងការពង្រឹងសមភាពយេនឌ័រ។

លោកជំទាវ Carmen Moreno ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជាមានប្រសាសន៍ថា *"ការរាតត្បាតជាសកលនៃវីរុសកូរ៉ូណា ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការ និងសាមគ្គីភាព។ ក្រុមអឺរ៉ុបរួមគ្នាឈរជាមួយកម្ពុជាក្នុងពេលវេលាដ៏សែនពិបាកនេះ។ យើងត្រូវធ្វើការងាររួមគ្នា ដើម្បីធានាឱ្យមានការស្តារសេដ្ឋកិច្ចឡើងវិញប្រកបដោយចីរភាព និងរឹងមាំ ក៏ដូចជា ជួយកាត់បន្ថយផលប៉ះពាល់ដែលការរាតត្បាតជាសកលនេះបង្កលើជីវិតមនុស្ស ការងារ និងជីវភាពរស់នៅរបស់ពួកគេ។ ដើម្បីសម្រេចគោលដៅនេះ យើងប្រើប្រាស់ធនធានរបស់*

*យើងរួមគ្នា និងចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងនានា ជាមួយនឹងរដ្ឋាភិបាល ក៏ដូចជាប្រជាពលរដ្ឋកម្ពុជា ដើម្បីឆ្លើយតបចំពោះបញ្ហាប្រឈមជាសកលនេះ”។*

ការគាំទ្រដែលដៃគូអឺរ៉ុបផ្តល់ដល់ប្រទេសកម្ពុជា ផ្តោតលើ**អាទិភាពសំខាន់ៗចំនួនបី** ស្របតាមផែនការគោលស្តីពីការឆ្លើយតបចំពោះជំងឺកូវីដ-១៩ របស់កម្ពុជា៖

**ក្នុងការគាំទ្រដល់វិស័យសុខាភិបាល** ក្រុមអឺរ៉ុបរួមចំណែកដល់ការបង្កើនសមត្ថភាពស្រាវជ្រាវ និងធ្វើ តេស្តនៅក្នុងប្រទេសកម្ពុជា, គាំទ្រដល់ការអនុវត្តផែនការសកម្មភាពជាតិស្តីពីការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងពង្រឹងប្រព័ន្ធសុខាភិបាល។ ដៃគូអឺរ៉ុបកំពុងពង្រឹងការអនុវត្ត និងធ្វើការ កែសម្រួល តំរង់ទិសកម្មវិធីរបស់ខ្លួន អោយមកផ្តោតលើអាហារូបត្ថម្ភ អានាម័យផ្ទាល់ខ្លួន ការទទួលបានទឹកស្អាត និងអនាម័យបរិស្ថាន ដើម្បីឱ្យកាន់តែឆ្លើយតបចំពោះតម្រូវការដែលកើតមានក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនេះ។ ក្រុមអឺរ៉ុបផ្តល់ការគាំទ្រយ៉ាងខ្លាំងខ្លា ដល់អង្គការសុខភាពពិភពលោក និងរួមចំណែកផ្តល់ហិរញ្ញប្បទានដល់ កម្មវិធីដែលអនុវត្តដោយអង្គការនេះ នៅក្នុងប្រទេសកម្ពុជា។

នៅកាលៈទេសៈដែលការងារ មុខរបរចិញ្ចឹមជីវិត និងសន្តិសុខស្បៀងត្រូវប្រឈមនឹងគ្រោះថ្នាក់ ដៃគូអឺរ៉ុបរួមចំណែកផ្តល់ការ**គាំទ្រដល់ប្រជាពលរដ្ឋ មុខរបរចិញ្ចឹមជីវិត និងការងាររបស់ពួកគេ**, រហូតដល់ក្រុមដែលងាយរងគ្រោះជាងគេ តាមរយៈកម្មវិធីគាំពារសង្គម អាហារូបករណ៍ ការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំ ការផ្តល់ជំនួយដល់ពលករ និងពលករទេសន្តរប្រវេសន៍ ដែលវិលត្រឡប់មកស្រុកកំណើតវិញ។ កម្មវិធីរបស់ក្រុមអឺរ៉ុបជួយគាំពារដល់ជីវភាពរស់នៅរបស់ពលរដ្ឋ តាមរយៈការអភិវឌ្ឍវារីវប្បកម្ម នេសាទ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ និងរួមចំណែកឆ្លើយបតចំពោះបញ្ហាប្រឈមពាក់ព័ន្ធនឹងការគ្រប់គ្រងវិបត្តិមីក្រូហិរញ្ញវត្ថុ។

អឺរ៉ុបនឹងធ្វើការងារជាមួយប្រទេសកម្ពុជា ដើម្បី**គាំទ្រដល់ការស្តារខឿនសេដ្ឋកិច្ច និងការបង្កើតការងារ**។ ការគាំទ្ររបស់ក្រុមអឺរ៉ុប នឹងរួមចំណែកពង្រឹងវិស័យសំខាន់ៗនៃសេដ្ឋកិច្ច ដែលក្នុងនោះរួមមានការវិនិយោគ សាធារណៈ ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ច ប្រសិទ្ធភាពថាមពល និងការស្តារឡើងវិញ ដែលគិតគូរពីបរិស្ថាន។ កម្មវិធី និងគម្រោងរបស់អឺរ៉ុប នឹងរួមចំណែកកសាងភាពធន់ក្នុងវិស័យឯកជន និង គាំទ្រដល់ការបង្កើត ការងារធានាឱ្យមានការស្តារសេដ្ឋកិច្ចឡើងវិញឱ្យបានរឹងមាំ ក៏ដូចជាការកសាងសេដ្ឋកិច្ចមួយដែលកាន់តែមាន ចីរភាព បរិយាប័ន្ន និងភាពធន់ ស្របតាមរបៀបវារៈឆ្នាំ ២០៣០ និងកិច្ចព្រមព្រៀងទីក្រុងប៉ារីស។

ការគាំទ្រក្នុងទឹកប្រាក់ចំនួន ៩៨៣ លានអឺរ៉ូ (ស្មើនឹង ៩៨៣ លានដុល្លារ ឬ ១.៩៩០ ប៊ីលានរៀល) ដែលជាការបញ្ចូលគ្នានូវថវិកាវិភាជន៍ថ្មី ថវិកាដែលបានវិភាជន៍តាមកម្មវិធី និងថវិកាដែលត្រូវបានបង្វែរទិសដៅ ត្រូវបានផ្តល់តាមរយៈស្ថាប័នរាជរដ្ឋាភិបាល និងអង្គការជាដៃគូ ដែលក្នុងនោះរួមមានអង្គការសង្គមស៊ីវិលផងដែរ។

* *ក្រុមអឺរ៉ុបរួមមានសហភាពអឺរ៉ុប និងរដ្ឋជាសមាជិករបស់ខ្លួន។ នៅក្នុងប្រទេសកម្ពុជា ក្រុមអឺរ៉ុបទទួលបានការចូលរួមពីប្រទេសស្វីស ដែលជាដៃគូអឺរ៉ុបរបស់យើង។*

*Encl. Team Europe Infographic - 1 page*